0137400017

# បញ្ជីសារពើភ័ណ្ឌ
# បេតិកភណ្ឌវប្បធម៌អរូបីយ៍កម្ពុជា

Reçu CLT / CIH / ITH
Le 21 AOUT 2017
N° 0394

Reçu CLT / CIH / ITH
Le 31 MARS 2017
N° 0167



# Inventory of Intangible Cultural Heritage of Cambodia

UNESCO
PHNOM PENH

Ministry
of Culture
and Fine Arts

**Lakhaon Preah Reach Troap Lakhaon Kbach Boran**

*See Classical Dance / Royal Ballet, page 21*

**Seak Samai**

*See Circus Drama, page 85*

**Lakhaon Khaol (Male Masked Theatre)**

*Lakhaon khaol* is one of the oldest forms of Cambodian performing arts practiced as early as the Angkor period. It is believed to have started approximately in the 9th century in accordance with bas-reliefs found on Angkor temple walls. During this Angkor period, *lakhaon khaol* was developed as an entirely male version of Khmer classical court dance.



The exact reasons are still unknown but some research has pointed to the form growing out of a religious context in which Brahmanism was in conflict with Buddhism during the reign of King Jayavarman VIII (1243-1295). In this time, many female dancers were killed and others were taken on as concubines. Training male dancers was an opportunity to recreate a dance form based on Buddhist doctrines.

The only story specifically performed by *lakhaon khaol* is the *Reamker*, the Khmer version of the Ramayana. The performance is accompanied by story telling, with the narrators playing a key role in directing the performance. It is accompanied by the traditional *pin peat* orchestra.

*Lakhaon khaol* was very popular in the Lon Nol regime and later became a favorite of King Sihanouk. At that time, there were eight professional troupes. The troupes were disbanded during the war and today the only original troupe remaining is that of "Wat Svay Angdet", 15 kilometres from Phnom Penh. Two new troupes have formed since the war, which includes Kompong Thom troupe and the troupe of the National Theater (Department of Performing Arts of the Ministry of Culture and Fine Arts).

Today, *Lakhaon khaol* forms part of the curriculum at the Royal University of Fine Arts.

**Top and below:**
**Artists of Department of Performing Arts, Chaktomuk Theatre, 2001**



## Lakhaon Khaol
(Male Masked Theatre)
(cont'd)

**Lakhaon Khaol Troupes which existed before 1975:**
- Lakhaon Khaol Troupe of Wat Phnom Sampeou, Battambong province
- Lakhaon Khaol Troupe of Pursat province
- Lakhaon Khaol Troupe of Wat Svay Angdet, Khum Sarikakeo, Srok Lavea Em, Kandal province
- Lakhaon Khaol Troupe of Phum Toek Khleang, Kandal province
- Lakhaon Khaol Troupe of Koh Reas, Kandal Province
- Lakhaon Khaol Troupe of Koh Oknhatey, Srok Khsach Kandal, Kandal province
- Lakhaon Khaol Troupe of Barung, Srok Khsach Kandal, Kandal province
- Lakhaon Khaol Troupe of Srok Ken Svay, Kandal province
- Lakhaon Khaol Troupe of The National Conservatory of Performing Arts

**Famous Lakhaon Khaol Teachers (deceased):**

Lakhaon Khaol Troupe of Battambang province:
Duch Kroeum, role of *yeak* (giant)
Duch Roeu, role of *yeak* (giant)
Duch Ang, role of *sva* (monkey)

Lakhaon Khaol Troupe of Wat Svay Angdet: (all deceased)
Em, role of *yeak* (giant)
Soun, role of *sva* (monkey)
Soum, role of *sva* (monkey)
Sam Bor, role of *sva* (monkey)
Soy, story-teller
Reth, role of clown

**Famous teachers who survive today:**
Ros, role of *yeak* (giant)
Sruon, role of *yeak* (giant)
Sun Reth, role of *neay rong* (male role)
Huot Ling Pouv, role of *neang* (female role)
Lim Pen, Lay Houn, Oeun and Mean, story-tellers
Hul Thouk, role of clown
Lach, musician

**List of Various Repertory:**

*Chambang Peal Yub* (The Battle at Night), choreographed by Prof. Chheng Phon, Mr. Proeung Chhleng, Mr. Pok Sarann, and Mr. Chheng Daravuth.

*Chambang Kompikar* (The Battle of Kompikar) choreographed by Mr. Sdoeung Cham Roeurn, and Mr. Pok Sarann.

*Preah Ream Choul Kaot Banhchhaot Neang Seda* (Preah Ream Enters The Body Um to Cheat Neang Sita), choreographed by Mr. Pok Sarann and Mr. Mom Soth under the direction of Mr. Mao Keng.

*Sida Luy Phloeung* (Neang Sita Walking on Flames), choreographed by Mr. Pok Sarann and Mr. Seng Sam An, under the direction of Prof. Hang Soth and Mr. Mao Keng.

**Others:** *Preah Ream Der Tes* (Preah Ream's Exile in the Forest), *Preah Ream Chong Tnaol*, (Preah Ream Building a Dike to Lanka), *Sangkream Virul Chambang*, (The Battle of Virul Chambang), *Sangkream Indrachit* (The Battle of Indrachit) etc.

## Lakhaon Poul Srei
(Female Masked Theatre)

*Lakhaon poul srei* is the female version of *lakhaon khaol* (classical male masked theater), which literally translates as 'female narration'. Both forms combine classical theater and dance and are accompanied by the traditional *pin peat* orchestra. Unlike *lakhaon lhaol*, which use a separate group of narrators, *lakhaon poul srei* dancers take turns narrating while other members continue to dance. The dancers often lift their masks and narrate directly to the audience.

*Lakhaon poul srei* is believed to have originated from the Kingdom of Udong between 1618-1628 during the reign of King Preah Bat Chey Chetha II. In 1878, Ms. Chinh, a great art teacher from Koh Oknheatey, came to teach *lakhaon poul srei* in Vat Keansvay Krao. Today, one of her students, a 70 year-old woman, Ms. Chea Samut, has taken a lead role in reviving *lakhaon poul srei* and currently teaches this drama form to students at Vat Keansvay Krao, after having disappeared for more than 40 years.

This drama was re-introduced by Prof. Pich Tum Kravel, Prof. Hang Soth, Mr. Chin Neak, Mr. Sok Sam Oeun, Ms. Pen Sokchea, Ms. Hul Phoeurn Nari, and Mr. Ang Kim Or. A production entitled *Chey Sen* was performed at Chaktomuk Theatre with the support of the Ministry of Culture and Fine Art and UNESCO on July 2, 1999.

0137400016

Reçu CLT CIH ITH
Le 21 AOUT 2017
N° 0394



## ៣. ល្ខោនខោល

ល្ខោនខោលជាប្រភេទល្ខោនយ៉ាងចំណាស់មួយក្នុងចំណោមទម្រង់សិល្បទស្សនីយភាពចាស់ៗដទៃទៀតរបស់កម្ពុជា ដែលឃើញមាននៅដើមសម័យអង្គរ។ គេជឿថា ល្ខោននេះកើតឡើងប្រហែលនៅក្នុងសតវត្សទី៩ ដោយសំអាងលើចម្លាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្ត។ ក្នុងសម័យអង្គរនេះហើយដែលល្ខោនខោលបានវិវឌ្ឍចេញពីល្ខោនព្រះរាជទ្រព្យទៅជាល្ខោនដែលសម្តែងដោយមនុស្សប្រុសសុទ្ធ។

ហេតុផលពិតប្រាកដ គឺពុំដឹងថាយ៉ាងណានោះទេ តែផ្អែកលើការស្រាវជ្រាវមួយចំនួនបានបង្ហាញថា ទម្រង់ល្ខោននេះគឺកើតចេញដោយសារតែវិបត្តិសាសនា ពោលគឺរវាងព្រហ្មញ្ញសាសនា និងពុទ្ធសាសនានៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័ន (ទី៨) (១២៤៣-១២៩៥)។ នៅក្នុងអំឡុងពេលនេះ អ្នករបាំស្រីជាច្រើនត្រូវគេសម្លាប់ ហើយខ្លះទៀតត្រូវគេចាប់យកទៅធ្វើជាស្រីស្នំ។ ការបង្ហឹកអ្នករបាំប្រុសជាឱកាសដើម្បីបង្កើតឡើងវិញនូវទម្រង់ល្ខោនដោយផ្អែកលើលទ្ធិពុទ្ធសាសនា។ ល្ខោនខោលគឺសម្តែងតែរឿងរាមកេរ្តិ៍ប៉ុណ្ណោះ។ ការសម្តែងល្ខោនខោលគឺមានអមដោយពំនោលសាច់រឿង ហើយអ្នកពំនោលនោះដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំការសម្តែងនោះ។ ភ្លេងលេងកំដរល្ខោនខោលគឺភ្លេងពិណពាទ្យ។

ល្ខោនខោលទទួលបានប្រជាប្រិយភាពខ្លាំងក្នុងសម័យ លន់ ណុល ហើយក្រោយមកក្លាយជាល្ខោនសព្វព្រះទ័យរបស់សម្តេច នរោត្តម សីហនុ។ នៅកាលនោះ មានក្រុមល្ខោនខោលអាជីព៦ក្រុម។ ក្រុមល្ខោនទាំងនោះត្រូវបែកខ្ញែកគ្នាអស់ក្នុងសម័យសង្គ្រាម។ សព្វថ្ងៃ មានក្រុមល្ខោនខោលដែលសេសសល់ពីមុនតែ១ក្រុមគត់ គឺ«ក្រុមល្ខោនខោលវត្តស្វាយអណ្តែត» ស្ថិតនៅប្រហែល១៥គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ក្នុងសម័យសង្គ្រាមនោះដែរ មានល្ខោនខោល២ក្រុមថ្មីទៀតបានបង្កើតឡើង គឺក្រុមល្ខោនខេត្តកំពង់ធំ និងក្រុមល្ខោនខោលជាតិ (សព្វថ្ងៃហៅថា នាយកដ្ឋានសិល្បទស្សនីយភាពនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ)។

បច្ចុប្បន្ន ល្ខោនខោលបានបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

•**ក្រុមល្ខោនខោលមុនឆ្នាំ១៩៧៥៖**

- ក្រុមល្ខោនខោលវត្តភ្នំសំពៅ ខេត្តបាត់ដំបង
- ក្រុមល្ខោនខោលខេត្តពោធិ៍សាត់
- ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត, ឃុំសារិកាកែវ, ស្រុកល្វាឯម, ខេត្តកណ្ដាល
- ក្រុមល្ខោនខោលភូមិទឹកឃ្លាំង ខេត្តកណ្ដាល
- ក្រុមល្ខោនខោលភូមិកោះរះ ខេត្តកណ្ដាល
- ក្រុមល្ខោនខោលកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល
- ក្រុមល្ខោនខោលភូមិបារ៉ាំង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល
- ក្រុមល្ខោនខោលស្រុកគៀនស្វាយ ខេត្តកណ្ដាល
- ក្រុមល្ខោនខោលអភិរក្សមន្ទីរជាតិនៃទស្សនីយភាព

•គ្រូល្ខោនខោលល្បីៗដែលបានចែកស្ថានទៅ៖

- ក្រុមល្ខោនខោលខេត្តបាត់ដំបង៖ ឌុច គ្រៀម (តួយក្ស), ឌុច រៀ (តួយក្ស), ឌុច អាង (តួស្វា)។
- ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត៖ អ៊ឹម (តួយក្ស), ស៊ុន (តួស្វា), ស៊ុម (តួស្វា), សំបូរ (តួស្វា), សយ (គ្រូពំនោល), វ៉េត (តួត្លុក)។

•គ្រូល្ខោនល្បីៗដែលនៅរស់៖

- ក្រុមល្ខោនខោលវត្តស្វាយអណ្ដែត៖ រស់ (តួយក្ស), ស្រ៊ូន (តួយក្ស), ស៊ុន រិទ្ធិ (តួនាយរោង), ហួត (តួនាង), ពៅ (តួនាង), លឹម ប៉ែន (អ្នកពំនោល), ឡាយ ហ៊ន (អ្នកពំនោល), អ៊ីន (អ្នកពំនោល), មៀន (អ្នកពំនោល), ហ៊ុល ធូក (តួត្លុក), ឡាច (អ្នកភ្លេង)។

•ស្នាដៃដែលបានបង្កើតនិងសម្តែង៖

- ចម្បាំងពេលយប់ បង្កើតដោយលោកសាស្ត្រាចារ្យ ឆេង ផុន, លោក ព្រឿង ឈៀង, លោក ប៉ុក សារ៉ាន់ និងលោក ឆេង តារាវុធ។

- ចម្បាំងកុម្ភកាណ៌ បង្កើតដោយលោក ស្តើង ចំរើន និងលោក ប៉ុក សារ៉ាន់។

- ព្រះរាមចូលកោដ្ឋបញ្ឆោតនាងសីតា បង្កើតដោយលោក ប៉ុក សារ៉ាន់, លោក មុំ សុត កែសម្រួលដោយ លោក មៅ កេង

- ស្នាដៃដទៃទៀតមាន៖ ព្រះរាមដើរទេស, ព្រះរាមចងថ្នល់, សង្គ្រាមវិរុលចម្បាំង, សង្គ្រាមឥន្ទ្រជិត។ល។



ការសម្តែងល្ខោនខោល ដោយក្រុមសិល្បករ នាយកដ្ឋានសិល្បៈទស្សនីយភាព
នៅសាលសន្និសីទចតុម្មុខ ឆ្នាំ២០០១

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

Ministry of Culture and Fine Arts



# បញ្ជីសារពើភណ្ឌ

## មរតកវប្បធម៌អរូបីកម្ពុជា

## Inventory of Intangible Cultural Heritage of Cambodia

២០១៦

2016

0137400006

**(Lkhon Khol Inventory English Translation)**

**3.3. *Lkhon Khol* (Male Masked Theatre)**

Community or Practitioner: The Community of Wat Svay Andet, The Troupe of Master Chea Hea, *the Cambodian Youth for Lkhon Khol,* and the Secondary School of Fine Arts and the Performing Arts Department of the Ministry of Culture and Fine Arts

Domain: Performing Arts

Date [of performance]: Wat Svay Andet: Fixed date (shortly after the Khmer New Year); The Troupe of Master Chea Hea and Ministry of Culture and Fine Arts: Un-fixed date (on demand)

*Lkhon Khol*, a kind of theatre with melodious recitation in which actors are all males, wear lacquer masks, and perform only episodes from *Reamker*, a Cambodian version of the Indian epic of *Ramayana*. This dance drama is accompanied by traditional *pin peat* orchestra. Costumes and ornaments are as magnificent as those of classical court dance regardless whether the troupes belong to farmers or the city people.

Based on epigraphic studies, scholars believe that *Lkhon khol* has derived from the *bhani* theater, a form of dramatic entertainment with a narrative told by reciter, existed since the Angkor period ($9^{th}$ –$14^{th}$ centuries CE).

As one can observe, today there are two purposes of *Lkhon Khol* performance: for purely for entertainment or as a part of religious ceremonies and mainly performed for ritual purposes. The first, for instance, are the troupe of Master Chea Hea in Battambang province; it is for-hire by local communities to perform for entertainment in religious ceremonies; and in Phnom Penh, there are, for instance, an artist association, *the Cambodian Youth for Lkhon Khol,* and the Secondary School of Fine Arts and the Performing Arts Department of the Ministry of Culture and Fine Arts that are performed for promoting the form and in special national events.

The second is deeply rooted in the community of Wat Svay Andet, a Buddhist Monastery, which is formed by about more than 1100 family of Tak Skor village (Sarika Keo commune) and Peam Ta Ek (Peam Oknha Ong commune), Lvea Em district, Kandal province.

*Although Lkhon Khol Wat Svay Andet* is performed as a part of entertainment, it mainly serves ritual purpose: bringing about happiness and prosperity, warding off calamities, and particularly appealing for sufficient rain for the coming rice cultivation season. Villagers of this community take pride in safeguarding this heritage in the challenging current context of globalization and modern technology. The performance seems to be social obligation of the whole community in contributing either labour or giving financial support. All performers are villagers, not professional artists. Those who use to perform continue to perform and they also help training those young males who love *Lkhon Khol*. Grandparents and parents also encourage their grandsons and sons to take part in *Lkhon Khol* training. Interestingly, performers seem to feel "socially obliged" to return from their private businesses far away from the village to participate in the annual performance.

The episodes that have been performed by artists of the Ministry of Culture and Fine Arts:

- *Chambang Pel Yob* (The Battle at Night), directed by Master Chheng Phon, Mr. Proeung Chhieng, Mr. Pok Sarann and Mr. Chheng Daravuth.
- *Chambang Kumbhakar* (The Battle of Kumbhakar), directed by Mr. Sdoeung Chamroen and Mr. Pok Sarann.

- *Preah Ream Chol Kaot Banhchhaot Neang Sita* (Preah Ream enters the Urn to Cheat Neang Sita), directed by Mr. Pok Sarann and Mr. Mom Soth under the supervision of Mr. Mao Keng.
- *Sita Luy Ploeng* (The Ordeal of Sita), directed by Mr. Pok Sarann and Mr. Seng Sam An, under the suppervision of Prof. Hang Soth and Mr. Mao Keng.
- Others: *Preah Ream Doer Tes* (Preah Ream on Exile in the Forest), *Preah Ream Chong Thnol* (Preah Ream Constructing the Bridge to Langka), *Sangkream Virul Chambang* (The Battle of Virul Chambang), *Sangkream Indrachit* (The Battle of Indrachit), etc.

• Famous Lkhon Khol Master, who already passed away:
- At Wat Svay Andet: Em (demon role), Sun (monkey role), Sum (monkey role), Sambor (monkey role), Soy (reciter), Reth (clown role).
- At Battambang province: Duch Kroeun (demon role), Duch Roeu (demon role), Duch Ang (monkey role).

• Famous masters who survive today:
- At Wat Svay Andet: IM Saruon (demon role), Mr. HENG Soa (Mokey role), Mr. MEACH Mean (reciter), Mr. POK Oeun (reciter), Mr. MOUL Lach (demon role and musician).
- At Battambang province: there is Master Chea Hea, who has been named as a National Human Living Treasure in 2012.

• Description of the figures:
1. *Lkhon Khol* performance (Photo credit: Amrita Performing Arts, 2005)
2. Spiritual Ritual for *Lkhon Khol* (Photo credit: Amrita Performing Arts, 2005)
3. *Lkhon Khol* performed by the troupe of MCFA (Photo credit: San Phalla, 2016)
4. *Lkhon Khol* performed by the troupe of Wat Svay Andet (Photo credit: Wat Svay Andet, 2016)
5. *Lkhon Khol* performed by the troupe of Wat Svay Andet (Photo credit: Wat Svay Andet, 2016)
6. *Lkhon Khol* masks of the troupe of Master CHEA Hea (Photo credit: San Phalla, 2016)
7. Young schoolboys take part in weekly *Lkhon Khol* trainings (Photo credit: San Phalla, 2016)

• Reference cited:
Prep Chan Mara, 2009, *Lkhon Khol Wat Svay Andet*, Reyum, Phnom Penh.
Ministry of Culture and Fine Arts and UNESCO, 2004, *Inventory of Intangible Cultural Heritage of Cambodia*, Phnom Penh.

## ៣.៣. **ល្ខោនខោល**

*Lkhon Khol (Male Masked Theatre)*

| | |
|---|---|
| សហគមន៍ ឬ ទីតាំងប្រតិបត្តិ | វត្តស្វាយអណ្តែត, ក្រុមល្ខោនខោលរបស់លោកតា ជា ហ៊ា នៅខេត្តបាត់ដំបង, ក្រុមយុវជនល្ខោនខោលកម្ពុជា, នាយកដ្ឋានទស្សនីយភាពនិងសាលាមធ្យមវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ប្រភេទ | សិល្បទស្សនីយភាព |
| ពេលវេលា | ក្រោយចូលឆ្នាំ (វត្តស្វាយអណ្តែត), មិនកំណត់ពេល (ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រុមលោកតា ជា ហ៊ា) |



ល្ខោនខោល (រូប៖ អម្រិតាសិល្បៈ, ២០០៥)

### ពិពណ៌នា

"ល្ខោនខោល" ជាល្ខោនមួយបែបដែលពាក់មុខខ្មុកសម្តែង ហើយជាទូទៅតួអង្គសុទ្ធតែមនុស្សប្រុស និងសម្តែងតែឈុតឆាកក្នុងរឿងរាមកេរ្តិ៍ប៉ុណ្ណោះ។ ល្ខោននេះធ្វើកាយវិការតាមសំឡេងពោល ហើយកំដរដោយភ្លេងពិណពាទ្យ។ សម្លៀកបំពាក់ និងគ្រឿងអលង្ការសម្រាប់លេងល្ខោនខោលវិញក៏មានភាពប្រណីតពុំខុសពីល្ខោនព្រះរាជទ្រព្យប៉ុន្មានទេ មិនថាល្ខោនខោលនោះជារបស់អ្នកក្រុង ឬរបស់អ្នកស្រុកស្រែចម្ការឡើយ។

ផ្អែកទៅលើការសិក្សាតាមរយៈសិលាចារឹកបុរាណ អ្នកស្រាវជ្រាវយល់ថាល្ខោនខោលមានដើមកំណើតពីល្ខោន "ភាណី" ឬ "ភាន្និ" ជាប្រភេទល្ខោនដែលមានអ្នកពោលរៀបរាប់សាច់រឿង ហើយឃើញមានយ៉ាងហោចណាស់ក៏ចាប់ពីសម័យអង្គរ (ស.វ.៩-១២)មកដែរ។

យើងសង្កេតឃើញថា ល្ខោនខោលដែលសម្តែងសព្វថ្ងៃមានពីរបែប ម៉្យាងគឺដើម្បីកម្សាន្ត ឬជាប់នឹងកិច្ចសាសនាបន្តិចបន្តួច និងល្ខោនខោលដែលនៅជាប់ក្នុងជំនឿរបស់សហគមន៍។ ល្ខោនខោលប្រភេទទី១នោះ មានដូចជាក្រុមល្ខោនលោកតា ជា ហ៊ា នៅខេត្តបាត់ដំបងដែលជាក្រុមសម្រាប់ជួលសម្តែងកម្សាន្តក្នុងពិធីបុណ្យទាននានា។ ចំណែកនៅរាជធានីភ្នំពេញ មានក្រុមល្ខោនខោលនៃនាយកដ្ឋានសិល្បទស្សនីយភាព និងសាលាមធ្យមវិចិត្រសល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រុមល្ខោនខោលរបស់យុវជនល្ខោនខោលកម្ពុជា ដែលច្រើនតែសម្តែងសម្រាប់លើកតម្កើងល្ខោនខោល និងលេងកម្សាន្តក្នុងឱកាសពិសេសនានាក្នុងកម្រិតជាតិ។

ចំណែកល្ខោនប្រភេទទី២នោះ គឺជាប់ជាពិសេសជាមួយសហគមន៍វត្តស្វាយអណ្តែតដែលមានភូមិតាស្គរ និងភូមិពាមតាឯក (ស្រុកល្វាឯម ខេត្តកណ្តាល)

ជាចំណុះជើងវត្ត។ ល្ខោនវត្តស្វាយអណ្តែតពុំមែនគ្រាន់តែសម្រាប់កម្សាន្តសប្បាយប៉ុណ្ណោះទេ តែគេសម្តែងនៅក្នុងបរិបទជំនឿដែលគេជឿថា ពេលសម្តែងល្ខោននេះនឹងទទួលបាននូវសេចក្តីសុខ ចម្រុងចម្រើន បញ្ចៀសឧបទ្រពចង្រៃ ហើយពិសេសនោះ គឺទទួលបានទឹកភ្លៀងគ្រប់គ្រាន់និងកោតផលបរិបូរណ៍សម្រាប់រដូវដាំដុះខាងមុខ។ ចំពោះអ្នកស្រុកខ្លួនឯងផ្ទាល់យល់ថា ល្ខោននេះជាមរតកវប្បធម៌របស់ខ្លួន ហើយខិតខំព្យាយាមការពារតាមលទ្ធភាពដែលអាចធ្វើទៅបាន នៅក្នុងចរន្តនៃសាកលភាវូបនីយកម្ម និងបច្ចេកវិទ្យាទំនើប។ ការសម្តែងនេះទៀតសោតហាក់ជា "កាតព្វកិច្ច" របស់អ្នកស្រុកអ្នកភូមិទាំងមូល ដោយខ្លះចូលរួមជាធនធានខ្លះជាកម្លាំង។ រីឯអ្នកសម្តែងវិញគឺជាអ្នកភូមិ ពុំមែនជាអ្នកមានអាជីពខាងសម្តែងឡើយ។ អ្នកធ្លាប់សម្តែងរមែងមកសម្តែងបន្តទៀត ហើយថែមទាំងខិតខំជួយបង្ហាត់បង្រៀនកុមារ និងយុវជនដែលស្រឡាញ់ចូលចិត្តល្ខោនខោលនេះទៀតផង។ ចំណែកឯឪពុកម្តាយ យាយតា ក៏រមែងលើកទឹកចិត្តឲ្យកូន និងចៅមកហាត់រៀនដែរ។ ប្រការគួរឲ្យចាប់អារម្មណ៍មួយទៀតនោះគឺបើទោះបីអ្នកធ្លាប់សម្តែងបានចាកចេញពីភូមិ ទៅប្រកបរបរនៅទីឆ្ងាយយ៉ាងណាក៏ដោយ ក៏ពួកគាត់ហាក់មាន "កាតព្វកិច្ចសង្គម" តម្រូវឲ្យមកចូលរួមពេលមានពិធីសម្តែងម្តងៗ។

រឿងដែលបានដំឡើង និងសម្តែងដោយក្រុមសិល្បករក្រសួងវប្បធម៌និងវិចិត្រសិល្បៈដូចជា៖

- ចម្បាំងពេលយប់ ដំឡើងដោយលោក ឆេង ផុន, លោក ព្រឿង ឈាង, លោក ប៉ុក សារ៉ាន់, ឆេង តារាវុធ
- ចម្បាំងកុម្ភកាណ៌ ដំឡើងដោយលោក ស្តើង ចំរើន, លោក ប៉ុក សារ៉ាន់
- ព្រះរាមចូលគោដ្ឋបញ្ឆោតនាងសីតា ដំឡើងដោយលោក ប៉ុក សារ៉ាន់, លោក មុំ សុត និងដឹកនាំដោយ លោក ម៉ៅ កេង



សំពះគ្រូល្ខោនខោល ក្រុមនាយកដ្ឋានសិល្បៈទស្សនីយភាព (រូប៖ អម្រឹតាសិល្បៈ, ២០០៥)

- សីតាលុយភ្លើង ដំឡើងដោយលោក ប៉ុក សារ៉ាន់, លោក សេង សំអាន និងដឹកនាំដោយលោក ហង្ស សុត និងលោក ម៉ៅ កេង ក្រៅពីនេះមានស្នាដៃដទៃទៀតដូចជា៖ ព្រះរាមដើរទេស, ព្រះរាមចងថ្នល់, សង្គ្រាមវិរុលចម្បាំង, សង្គ្រាមឥន្ទ្រជិត...។

គ្រូល្ខោនខោលដែលបានចែកស្ថាន៖

នៅវត្តស្វាយអណ្តែត គឺមានលោកគ្រូ អ៊ឹម (គ្រូយក្ស), ស៊ិន (គ្រូស្វា), ស៊ុម (គ្រូស្វា), សំបូរ (គ្រូស្វា), សយ (គ្រូពោល), រ៉េត (តួត្លុក)។ រីឯនៅខេត្តបាត់ដំបងគឺមានលោកគ្រូ ឌុច គ្រឿន (គ្រូយក្ស), ឌុច រឿ (គ្រូយក្ស), ឌុច អាង (គ្រូស្វា)។

គ្រូល្ខោនខោលដែលនៅរស់៖

នៅវត្តស្វាយអណ្តែត គឺមាន អ៊ឹម សារួន (គ្រូយក្ស), ហេង សៅ (គ្រូស្វា), ម៉ិច មាន (គ្រូពំនោល), ប៉ោក អ៊ីន (គ្រូពំនោល), និង មូល ឡាច (គ្រូយក្សនិងគ្រូភ្លេង)។ ចំណែកនៅខេត្តបាត់ដំបងមានលោកគ្រូ ជា ហ៊ា ដែលកាលពីឆ្នាំ២០១២ ត្រូវព្រះមហាក្សត្រផ្តល់គោរមងារថ្នាក់ជាតិជា "មរតកមនុស្សរស់"។



ល្ខោនខោលក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
(រូប៖ សាន ផល្លា, ២០១៦)



ល្ខោនខោលវត្តស្វាយអណ្តែត (រូប៖ វត្តស្វាយអណ្តែត, ២០១៦)



ល្ខោនខោលវត្តស្វាយអណ្តែត (រូប៖ វត្តស្វាយអណ្តែត, ២០១៦)



មុខសម្រាប់ពាក់សម្តែងល្ខោនខោលរបស់ក្រុមលោកតា ជា ហ៊ា (រូប៖ សាន ផល្លា, ២០១៦)



ក្មេងក្នុងសហគមន៍វត្តស្វាយអណ្តែតហាត់រៀនសម្តែងល្ខោនខោល
(រូប៖ សាន ផល្លា, ២០១៦)

## ឯកសារពិគ្រោះ

ព្រាប ចាន់ម៉ារ៉ា, ២០០៩, ល្ខោនខោលវត្តស្វាយអណ្តែត, រ៉េយំ, ភ្នំពេញ។

Ministry of Culture and Fine Arts and UNESCO, 2004, Inventory of Intagible Cultural Heritage of Cambodia, Phnom Penh.